State Government Victoria
Department of Education and Early Childhood Development

Literacy tips to help your child
Before School - Year 2
Khmer

# គន្លឹះអក្ខរកម្មខ្លះៗ ដើម្បីជួយកូនរបស់អ្នក

មុនចូលសាលា - ថ្នាក់ទី២



កុមារ
រាល់រូប
ឱកាស
គ្រប់យ៉ាង







# ការជួយកូនរបស់អ្នកឲ្យចេះអាន សរសេរ ស្តាប់ និង និយាយ

## ការប្រើសកម្មភាពប្រចាំថ្ងៃដើម្បីផ្សារភ្ជាប់ទំនាក់ទំនងនៅក្នុងគ្រួសារ



- ចែករំលែកនូវចម្រៀង និងពាក្យកាព្យ ព្រមទាំងជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកចូលរួមជាមួយផង។
- ស្តាប់នូវអ្វីដែលកូនរបស់អ្នកនិយាយ និងឆ្លើយតបវិញទៅនឹងគំនិតផ្សេងៗរបស់ពួកគេជាមួយនឹងសំណួរ និងសួររកព័ត៌មានបន្ថែម។
- ចង្អុលបង្ហាញ និងនិយាយអំពីតួអក្សរ និងពាក្យពេចន៍ទាំងឡាយដែលនៅជុំវិញខ្លួនអ្នក។ ឧទាហរណ៍ ដូចជាប្រអប់ដាក់អាហារពេលព្រឹក, ស្លាកលេខរថយន្ត និងសញ្ញាផ្សេងៗជាដើម។
- ធ្វើការចម្អិនម្ហូបអាហារអ្វីមួយរួមគ្នា។ អានក្បួនធ្វើម្ហូបឲ្យឮៗ និងនិយាយបណ្តើរធ្វើបណ្តើរនូវអ្វីដែលអ្នកកំពុងធ្វើ។
- ចូលរួមជាមួយនឹងបណ្ណាល័យគ្រឿងក្មេងលេង និងជ្រើសរើសគ្រឿងក្មេងលេងរួមគ្នា។
- អាននូវក្រដាស ឬខិតប័ណ្ណផ្សាយពាណិជ្ជកម្មលក់របស់របរផ្សេងៗ ហើយពិភាក្សាអំពីអ្វីៗដែលគេកំពុងលក់ចុះថ្លៃ។
- និយាយជជែកលេងអំពីរូបថតក្រុមគ្រួសារ និងប្រវត្តិ រឿងរ៉ាវផ្សេងៗ។

## ការនិទានរឿង

ការនិទានរឿង គឺជាវិធីមួយដ៏ល្អបំផុតក្នុងការពង្រីកជំនាញស្តាប់ និងខាងភាសារបស់កូនអ្នក ក៏ដូចជាការបើកគំនិតឲ្យពួកគេមានក្តីស្រមៃផងដែរ។ អ្នកអាចនិទានរឿងប្រាប់កូន ឬក៏ជំរុញលើកទឹកចិត្តឲ្យកូនអ្នកនិទានរឿងប្រាប់វិញ។

ការនិទានរឿងអាចនិយាយអំពី៖

- តួអង្គដែលគេចូលចិត្តពីក្នុងសៀវភៅរឿង ឬក៏ពីកម្មវិធីទូរទស្សន៍ណាមួយ។
- សមាជិកក្រុមគ្រួសារណាម្នាក់ទៀត។
- គ្រឿងក្មេងលេងដែលកូនរបស់អ្នកចូលចិត្ត។



ក្រុមគ្រួសារគឺជាអ្នកមានឥទ្ធិពលមុនគេ និងជាប់លាប់ជាងគេចំពោះការលូតលាស់របស់កុមារ ហើយគ្រួសារក៏ដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការសិក្សារៀនសូត្ររបស់កុមារដែរ។

មានវិធីច្រើនយ៉ាងដែលអ្នកអាចបង្កើត និងគាំទ្រដល់ការវិវឌ្ឍជំនាញនៃការនិយាយ, ការស្តាប់, ការសរសេរ និងការអាននៃកូនរបស់អ្នកតាមរយៈការលេង និងសកម្មភាពប្រចាំថ្ងៃជាច្រើនរបស់គ្រួសារ។

ប័ណ្ណព័ត៌មាននេះផ្តល់ជាគំនិតខ្លះៗដែលអ្នក ឬសមាជិកគ្រួសារដទៃទៀតរបស់អ្នកអាចធ្វើជាមួយនឹងកូនរបស់អ្នកនៅក្នុងសកម្មភាពប្រចាំថ្ងៃនានាដើម្បីពង្រឹង និងពង្រីកចំណេះអក្ខរកម្មរបស់ពួកគេ។

ប្រសិនបើអ្នកមានទំនុកចិត្តខ្លួនឯងនោះ ការឲ្យកូនរបស់អ្នកចូលរួមនៅក្នុងសកម្មភាពទាំងនេះ ជាភាសាទីមួយរបស់ពួកគេ និងជាភាសាអង់គ្លេសគឺអាចហុចនូវប្រយោជន៍យ៉ាងល្អ។

ប័ណ្ណព័ត៌មាននេះក្នុងទម្រង់អេឡិចត្រូនិកក៏មានជូនជាភាសាអង់គ្លេស និង២៣ភាសាដទៃទៀតដែរពីវ៉ិបសាយថ៍គ្រួសារជាដៃគូនៅក្នុងការសិក្សា៖ **www.education.vic.gov.au/about/directions/familiesaspartners/schools/connecting.htm**

## តើខ្ញុំអាចទទួលជំនួយពីណា?

### គ្រូរបស់កូនអ្នក

គ្រូរបស់កូនអ្នកអាចផ្តល់ឱវាទអំពីវិធីដែលអ្នកអាចជួយពង្រឹង និងពង្រីកចំណេះដឹងខាងអក្ខរកម្មនៃកូនរបស់អ្នក។ ប្រធានបទខ្លះៗដែលអ្នកអាចពិភាក្សាជាមួយនឹងលោកគ្រូអ្នកគ្រូរួមមាន៖

- កម្រិតជោគជ័យលើកិច្ចការអក្ខរកម្មនៃកូនរបស់អ្នក។
- គោលដៅអក្ខរកម្មផ្សេងៗដែលកូនរបស់អ្នកកំពុងតែខិតខំរៀនដើម្បីសម្រេចឲ្យបាន និងរបៀបដែលអ្នកអាចជួយគាំទ្រកូនរបស់អ្នកនៅក្នុងការសម្រេចទិសដៅទាំងនេះ។
- វិធីសាស្ត្រផ្សេងៗដែលអ្នកអាចប្រើដើម្បីជួយកូនរបស់អ្នកនៅក្នុងផ្នែកដែលកូនរបស់អ្នកមានការលំបាក។

### ធនធានឯកសារ និងសម្ភារនៅលើបណ្តាញអ៊ីនធើរណិត

វ៉ិបសាយថ៍ *Connect-Primary* ថ្មីរបស់រដ្ឋាភិបាលរដ្ឋវិចថូរៀបង្កលក្ខណៈងាយស្រួលនៅក្នុងការភ្ជាប់ទៅឧបករណ៍សិក្សាល្អៗពីកុំព្យូទ័ររបស់អ្នកនៅផ្ទះ, ពីកុំព្យូទ័រនៅបណ្ណាល័យក្នុងតំបន់ ឬក៏អាចភ្ជាប់ពីកុំព្យូទ័រនៅសាលារៀនរបស់អ្នក។

បើកមើលវ៉ិបសាយថ៍ *Connect-Primary* នៅអាសយដ្ឋាន **http://www.education.vic.gov.au/primary**

វ៉ិបសាយថ៍ផ្សេងៗដែលមាននៅក្នុងវ៉ិបសាយថ៍ *Connect-Primary* ត្រូវបានលោកគ្រូអ្នកគ្រូឆែកមើល ដើម្បីធានាឲ្យបានថាវ៉ិបសាយថ៍ទាំងនោះសមរម្យសម្រាប់កុមារ។

ត្រូវចងចាំថា ប្រសិនបើអ្នកចូលមើលវ៉ិបសាយថ៍ដទៃទៀតដែលមិនមានរាយឈ្មោះនៅក្នុងបញ្ជីលើវ៉ិបសាយថ៍ *Connect-Primary* ទេនោះ ដើម្បីសុវត្ថិភាព អ្នកមិនគួរផ្តល់ព័ត៌មានលម្អិត ដូចជាឈ្មោះរបស់អ្នក ឬឈ្មោះពេញនៃកូនរបស់អ្នក, សាលារៀន, លេខទូរស័ព្ទ ឬក៏អាសយដ្ឋាន ទៅឲ្យជូនណាម្នាក់ដែលអ្នកមិនស្គាល់នៅលើបណ្តាញអ៊ីនធើរណិតឡើយ។

*Ultranet* គឺជាប្រព័ន្ធថ្មីមួយតាមអ៊ីនធើរណិតដែលផ្តល់ជូនអ្នកនូវព័ត៌មានអំពីការសិក្សារៀនសូត្រនៃកូនរបស់អ្នកនៅឯសាលារៀន។ ប្រព័ន្ធថ្មីនេះគឺជាប្រព័ន្ធប្រើទូទាំងរដ្ឋដែលមានសុវត្ថិភាពដែលសិស្ស, មាតាបិតា និងលោកគ្រូអ្នកគ្រូអាចបើកមើលបានតាមអ៊ីនធើរណិត។ បើកមើលវ៉ិបសាយថ៍ *Ultranet* នេះនៅ៖ **www.education.vic.gov.au/about/directions/ultranet/benefits/parents.htm**

ខាងក្រោមនេះគឺជាគំនិតខ្លះៗសម្រាប់ជាជំនួយក្នុងការចាប់ផ្ដើមការនិទានរឿង៖

- ធ្វើឲ្យរឿងនោះជារឿងរំភើបរីករាយ ដោយមានបញ្ចូលសំឡេងខុសៗគ្នា មានតុក្កតា ហើយប្រើឧបករណ៍ផ្សេងៗ ឬប្រើម្រាមដៃសម្រាប់សម្ដែង។
- ចាប់ផ្ដើមពីអ្វីមួយដែលធ្វើឲ្យកូនរបស់អ្នកចូលចិត្ត។
- បង្កើតឲ្យមាននូវតួអង្គណាមួយ និងឆាកឈុតនៃសាច់រឿង។

## ការអានជាមួយគ្នា

ការអានគឺជាវិធីមួយមានសារៈសំខាន់ដើម្បីភ្ជាប់ទំនាក់ទំនងរវាងពាក្យសម្ដីនិយាយ និងពាក្យដែលគេសរសេរ។

ការអានឲ្យកូនអ្នកស្ដាប់គឺជាការមួយមានតម្លៃដែលត្រូវធ្វើ។ ខាងក្រោមនេះគឺជាគំនិតខ្លះៗសម្រាប់ជាជំនួយ៖



- ជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកជ្រើសរើសសៀវភៅ ទស្សនាវដ្ដី កាតាឡុក រឿងផ្សេងៗទៀតដែលមាននៅក្នុងម៉ាល់ធីមីឌៀ ឬក្នុងថាសឌីវីឌីជាដើម។
- ពិភាក្សាអំពីរូបភាពផ្សេងៗនៅក្នុងសៀវភៅណាមួយ ហើយជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកនិយាយពិពណ៌នាអំពីរូបភាពទាំងនោះ។
- ចែករំលែកនូវសៀវភៅរូបភាពដែលពុំមានសរសេរពាក្យពេចន៍ ដើម្បីជួយបង្កើតនូវក្ដីស្រមើស្រមៃ គំនិត និងពាក្យពេចន៍ផ្សេងៗ តាមរយៈការឲ្យឈ្មោះដល់វត្ថុដែលមាននៅក្នុងរូបភាពទាំងនោះ។
- អានម្ដងហើយម្ដងទៀតនូវសៀវភៅ និងរឿងផ្សេងៗដែលកូនរបស់អ្នកចូលចិត្ត។
- ជួយកូនរបស់អ្នកឲ្យបង្កើតសៀវភៅខ្លួនឯងដោយមានរូបភាពជាច្រើន ហើយឲ្យពួកគេអានរឿងនោះឲ្យអ្នកស្ដាប់។

*ការអានជាមួយ* កូនរបស់អ្នកនឹងចាប់ផ្ដើមនៅពេលដែលកូនរបស់អ្នកបានដឹងយល់ខ្លះៗអំពីសាច់រឿង ហើយអាចចាប់ផ្ដើមការអានខ្លះដោយខ្លួនពួកគេ។

នៅពេលដែលកូនរបស់អ្នក*អានឲ្យអ្នកស្ដាប់* ផ្ដល់ពេលឲ្យពួកគេគិតអំពីពាក្យពេចន៍ ហើយសួរសំណួរដល់ពួកគេ ដើម្បីឲ្យដឹងថា តើកូនរបស់អ្នកយល់នូវអ្វីដែលគេបានអាន ឬទេ។

ការបង្ហាញឲ្យកូនរបស់អ្នកដឹងនូវរបៀបដែលអ្នកអាន រាល់ថ្ងៃសម្រាប់គោលបំណងខុសៗគ្នាក៏ជារឿងសំខាន់ផងដែរចំពោះអ្នក ឧទាហរណ៍ ដូចជាការអាននូវក្បួនធ្វើម្ហូបទាំងឡាយ, ការអានកាតសួរសុខទុក្ខ, មើលប្រក្រតិទិន, បញ្ជីទិញទំនិញ, ផ្លាកបិទលើអាហារ, សេចក្ដីណែនាំផ្សេងៗ, ផែនទី, កាសែត, អ៊ីមែល, សញ្ញាផ្សេងៗ រួមទាំងវិបសាយថ៍ជាដើម។ល។




*ការពិភាក្សាអំពីសៀវភៅ* គឺជាផ្នែកដ៏សំខាន់មួយនៃការអាន។ និយាយជជែកលេងអំពីសៀវភៅនៅមុន, នៅក្នុងអំឡុងពេល និងក្រោយការអាន ហើយខំជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកនិយាយអំពីគំនិតរបស់គេ និងសួរសំណួរផ្សេងៗអំពីសៀវភៅនោះ។ ខាងក្រោមនេះគឺជាសំណួរខ្លះៗដែលអ្នកអាចសួរកូននៅពេលខុសៗគ្នា ដូចជាពេលមុន ពេលកំពុងអាន និងពេលក្រោយអានសៀវភៅ៖

- តើកូនចង់អានរឿងអ្វី?
- តើកូនចង់ជ្រើសរើសសៀវភៅដែលកូនដឹងឬយ៉ាងណា?
- មើលទៅក្របសៀវភៅ - តើកូនយល់ថាសៀវភៅនេះ និយាយអំពីអ្វីដែរ?
- តើអ្វីទៅដែលកំពុងកើតឡើងនៅក្នុងរូបភាព?
- តើកូនគិតថាអ្វីទៅដែលនឹងកើតឡើងបន្ទាប់ទៀត?
- តើផ្នែកណាមួយដែលកូនចូលចិត្តនៅក្នុងសៀវភៅនេះ?
- តើនរណាគេជាតួអង្គដែលកូនចូលចិត្តនៅក្នុងរឿងនោះ? តើហេតុអ្វីបានជាកូនចូលចិត្តតួអង្គនោះ?
- ប្រសិនបើកូនអាចផ្លាស់ប្ដូរសាច់រឿងចុងក្រោយនៅក្នុងសៀវភៅនេះ តើកូនចង់ផ្លាស់ប្ដូរអ្វីខ្លះ?

## គំនិតផ្សេងៗក្នុងការអាន



- សូមមើល និងសាកល្បងឆ្លើយចំណោទផ្សេងៗរួមគ្នា តាមរយៈការចុចនៅលើពាក្យ *Quiz* ដែលមានភ្ជាប់នៅលើវិបសាយថ៍ *FUSE* សម្រាប់កូនសិស្សថ្នាក់បឋមសិក្សា។
- សរសេរទុកនូវអ្វីដែលកូនរបស់អ្នកបានប្រាប់អ្នកអំពីបទពិសោធន៍ណាមួយ ហើយអានវាឡើងវិញរួមគ្នា។
- ទៅបណ្ណាល័យក្នុងតំបន់ ឬបណ្ណាល័យរបស់សាលា ដើម្បីទៅរើស និងអានសៀវភៅជាមួយគ្នា។
- ស្វែងរកនូវការពិតផ្សេងៗអំពីពិភពលោកតាមរយៈការចុចនៅលើពាក្យ *Find out* ដែលមានភ្ជាប់នៅលើវិបសាយថ៍ *FUSE* សម្រាប់កូនសិស្សបឋមសិក្សា។

- គូររូប និងផាត់ពណ៌គំនូរផ្សេងៗ អំពីទេសភាព ឬក៏តួអង្គនានា។ ចុចនៅលើពាក្យ *Draw* ដែលមានភ្ជាប់ នៅលើវ៉ិបសាយថ៍ *FUSE* សម្រាប់កូនសិស្សបឋមសិក្សា។



- ស្វែងរកពាក្យពេចន៍ដោយការប្រើវចនានុក្រម។
- និយាយពិភាក្សាអំពីកិច្ចការរបស់អ្នកនិពន្ធ និងអ្នកគូររូបភាព។
- ចង្អុលបង្ហាញនូវចំណុចសំខាន់ៗ អំពីសៀវភៅ - ក្របសៀវភៅ, ខ្នងសៀវភៅ, ទំព័រមាតិកា, ចំណងជើង។ល។

## ការអាន និងការសរសេរត្រូវដើរទន្ទឹមគ្នា

ការចេះសរសេរចាប់ផ្តើមឡើងពីការសរសេរខ្វៀក និងការគូររូបផ្សេងៗ។ នេះគឺជាជំហានដំបូងដ៏សំខាន់ និងគួរទទួលបាននូវការជំរុញលើកទឹកចិត្ត។ ផ្តល់ការគាំទ្រដល់កូនរបស់អ្នកឲ្យអានឮៗ នូវអ្វីដែលគេបានសរសេរ។ បង្កើតនូវកន្លែងណាមួយសម្រាប់ផ្ទុកទុក និងដាក់តាំងស្នាដៃសរសេររបស់ពួកគេ។

ប្រើប្រាស់បទពិសោធន៍របស់កូនអ្នក ដើម្បីបង្កើតនូវទំនាក់ទំនងផ្សារភ្ជាប់រវាងការនិយាយ ការសរសេរ និងការអាន។ ខាងក្រោមនេះគឺជាជំហានមួយចំនួនសម្រាប់អនុវត្ត៖

- ស្នើឲ្យកូនរបស់អ្នកនិយាយអំពីបទពិសោធន៍ណាមួយ ឬក៏អ្វីដែលធ្វើឲ្យពួកគេចូលចិត្ត។
- សួរកូនរបស់អ្នកថាតើផ្នែកណានៃការសន្ទនា ដែលពួកគេចង់សរសេរ។
- នៅពេលដែលកូនរបស់អ្នកកំពុងតែនិយាយ សូមសរសេរទុកនូវគំនិតរបស់ពួកគេ។ ប្រើភាសារបស់កុមារ។



- ស្នើឲ្យកូនរបស់អ្នកអានឡើងវិញនូវការសរសេរនោះ។
- កូនរបស់អ្នកអាចចង់គូររូប ឬក៏បង្កើតអ្វីមួយដែលស៊ីសង្វាក់គ្នាទៅនឹងការសរសេររបស់គេ។

## ឱកាសផ្សេងៗសម្រាប់ការសរសេររាល់ថ្ងៃនៅក្នុងគ្រួសារ៖

ដូចជាការអានដែរ ការសរសេរក្លាយទៅជាសកម្មភាពប្រចាំថ្ងៃនៅក្នុងគ្រួសារ។ អនុញ្ញាតឲ្យកូនរបស់អ្នកមើលអ្នកសរសេរ។

សូមសាកល្បងនូវគំនិតសរសេរខ្លះៗខាងក្រោមនេះនៅក្នុងគ្រួសារ៖

- សរសេរនូវបញ្ជីឈ្មោះអីវ៉ាន់ដែលត្រូវទិញនៅផ្សារ ឬក៏សរសេរនូវឈ្មោះអីវ៉ាន់ថែមទៀតចូលក្នុងបញ្ជី និងគូសលុបចោលនូវរបស់ដែលអ្នកទិញរួច ឬយកចេញពីស្បោង។



- ត្រូវមានក្តារខៀនមួយសម្រាប់ការសរសេរ និងអានសារក្នុងក្រុមគ្រួសារ។
- រៀបចំ និងសរសេរនូវបញ្ជីឈ្មោះមុខម្ហូបប្រចាំសប្តាហ៍របស់អ្នកជាមួយគ្នា។
- សរសេរចំណងជើង ឬការពិពណ៌នាខ្លីៗអំពីរូបថតនៅ ក្នុងក្រុមគ្រួសាររបស់អ្នកដាក់ចូលក្នុងអាល់ប៊ុមរូបថត។
- សរសេរផ្លាកផ្សេងៗសម្រាប់កិច្ចការគំនូរសិល្បៈ និងការច្នៃប្រឌិតទាំងឡាយរបស់កូនអ្នក។
- បង្កើត និងសរសេរកាតសួរសុខទុក្ខ កាតជូនពរថ្ងៃបុណ្យកំណើត និងកាតថ្លែងអំណរគុណផ្សេងៗ។
- ត្រូវមានប្រក្រតិទិនមួយក្នុងក្រុមគ្រួសារសម្រាប់ដាក់តាំង ហើយត្រូវកត់ត្រាទុកនូវព្រឹត្តិការណ៍ផ្សេងៗដែល ក្រុមគ្រួសារត្រូវធ្វើជុំគ្នា។ ត្រូវនិយាយពិភាក្សាអំពីព្រឹត្តិការណ៍ដែលខិតជិតមកដល់ជាមួយកូនរបស់អ្នក ឧទាហរណ៍ នៅទីណា នៅពេលណា ហើយនរណាខ្លះ នឹងទៅទីនោះ?

## រង្វាន់ពីអភិបាលរដ្ឋសម្រាប់ការខិតខំអាន

រង្វាន់ពីអភិបាលរដ្ឋសម្រាប់ការខិតខំអាន (Premier’s Reading Challenge) គឺជាវិធីមួយដ៏ល្អសម្រាប់កូនសិស្សក្នុងរដ្ឋវិចតូរិយ៉ាក្នុងការលើកកម្ពស់ការអានរបស់ពួកគេឲ្យកាន់តែប្រសើរឡើង។ មានការជំរុញលើកទឹកចិត្តឲ្យកូនសិស្សអាន និងសម្រេចបាននូវការអានសៀវភៅឲ្យបាន៣០ ក្បាលដើម្បីឈានដល់គោលដៅដែលបានកំណត់។ ប្រសិនបើកូនរបស់អ្នកទើបចាប់ផ្តើមរៀនអាន អ្នកអាចជួយពួកគេឲ្យមានបទពិសោធន៍ក្នុងការអានតាមរយៈការអានឲ្យស្តាប់ ឬអានជាមួយពួកគេ ហើយនិយាយពិភាក្សាអំពីរឿងនោះ ពាក្យពេចន៍ និងរូបភាពផ្សេងៗ។ សូមចូលឆែកមើលរង្វាន់ពីអភិបាលរដ្ឋសម្រាប់ការខិតខំអាននៅវ៉ិបសាយថ៍៖ **http://www.education.vic.gov.au/prc/default.htm**